**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ទីតាំងវិទ្យុផ្សាយសម្លេង AM ខេត្តបាត់ដំបង

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងលិខិតលេខ ១៥៧ ព.ម ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ក្រសួងពត៌មាន

-យោងចំណារបញ្ជូនលេខ ៥៦៤ ព.ម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ របស់ក្រសួងពត៌មាន

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងវិទ្យុផ្សាយសម្លេង AM ខេត្តបាត់ដំបងដែលមានផ្ទៃដី ៣៣២ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ១ ក្រុមទី៥ ភូមិ២០ ឧសភា ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដើម្បីធ្វើការផ្លាស់ប្តូរ ជាមួយថ្នូរនៃការសាងសង់អាគារថ្មី នៃស្ថានីយ៍ វិទ្យុផ្សាយសម្លេង AM ខេត្តបាត់ដំបង ។

**មាត្រា ២.-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគខាងលើនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ក្រសួងពត៌មាន ដោយសហការជាមួយសាលាខេត្តបាត់ដំបង និង មន្ទីជំនាញពាក់ព័ន្ធចំណុះខេត្តបាត់ដំបង ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល លើករណីសំណើដោះដូរទីតាំងនេះ ។

**មាត្រា ៣.-**

ការបំពេញបែបបទធ្វើកម្មសិទ្ធិត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- -ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការ រាជរដ្ឋាភិបាល
- -ដូចមាត្រា ៥
- -ឯកសារ-កាលប្បវត្តិ